# ការដាក់ពាក្យស្នើសុំសម្រាប់ថវិកាជំនួយថ្លៃសិក្សាថ្នាក់វិទ្យាល័យ

ប្រព័ន្ធជំនួយថ្លៃសិក្សាវិទ្យាល័យត្រូវបានកែប្រែដោយលុបចោលលក្ខខណ្ឌកំណត់ប្រាក់ចំណូលដូច្នេះមនុស្សជាច្រើនអាចទទួលជំនួយថ្លៃសិក្សាបាន

ដើម្បីទទួលបានការលើកលែងការបង់ថ្លៃសិក្សានៅវិទ្យាល័យ ត្រូវធ្វើការដាក់ពាក្យស្នើសុំ។

សូមអនុវត្តតាមសេចក្តីណែនាំនេះ ហើយដាក់ពាក្យនៅការិយាល័យរដ្ឋបាល ឲ្យបានមុនថ្ងៃទី ខែ ។

## ◆ ព័ត៌មានលម្អិតអំពីប្រព័ន្ធ

◆ ប្រសិនបើដាក់ពាក្យស្នើសុំប្រាក់ជំនួយថ្លៃសិក្សាសម្រាប់វិទ្យាល័យ និងស្ថាប័នអប់រំស្មើកម្រិតវិទ្យាល័យ ហើយត្រូវបានអនុម័ត នោះនឹងមិនចាំបាច់បង់ថ្លៃសិក្សាទេ។

◆ សិស្សដែលអាចទទួលបានសិទ្ធិនេះ
សិស្សដែលកំពុងសិក្សានៅវិទ្យាល័យ ឬស្ថាប័នអប់រំដែលមានកម្រិតស្មើ និងមានអាសយដ្ឋានស្នាក់នៅក្នុងប្រទេសជប៉ុន ហើយត្រូវបំពេញលក្ខខណ្ឌ ① **ឬលក្ខខណ្ឌណាមួយក្នុងចំណោម ② ដល់ ⑤**។※

① អ្នកដែលមានសញ្ជាតិជប៉ុន
＜អ្នកដែលមិនមានសញ្ជាតិជប៉ុន ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌខាងក្រោម（សូមមើលឧទាហរណ៍នៅទំព័រ 3）＞
② អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស（特別永住者）
③ អ្នកស្នាក់នៅអចិន្ត្រៃយ៍, ស្វាមី/ភរិយារបស់ជនជាតិជប៉ុន, ឬស្វាមី/ភរិយារបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍
④ អ្នកស្នាក់នៅរយៈពេលវែង(អ្នកដែលត្រូវបានទទួលស្គាល់ថាមានបំណងរស់នៅអចិន្ត្រៃយ៍នៅពេលអនាគត)
⑤ ស្នាក់នៅជាមួយគ្រួសារ
(អ្នកដែលបានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សានិងអនុវិទ្យាល័យក្នុងប្រទេសជប៉ុនហើយត្រូវបានទទួលស្គាល់ថាមានបំណងធ្វើការ និងរស់នៅជាបន្តបន្ទាប់នៅប្រទេសជប៉ុន បន្ទាប់ពីបញ្ចប់វិទ្យាល័យ ឬស្ថាប័នស្មើវិទ្យាល័យ)

※ សិស្សដែលធ្លាប់មានសាលាចាស់ហើយមានរយៈពេលសិក្សានៅវិទ្យាល័យ ឬស្ថាប័នអប់រំស្មើកម្រិតវិទ្យាល័យ សរុបលើសពី៣៦ខែ (ក្នុងករណីសិក្សាកម្មវិធីពេលយប់ ឬកម្មវិធីសិក្សាពីចម្ងាយ គឺលើសពី ៤៨ ខែ) នឹងមិនមានសិទ្ធិទទួលបានការឧបត្ថម្ភនេះទេ។

◆ **ដើម្បីទទួលបានការឧបត្ថម្ភ**
<u>សូមដាក់ពាក្យស្នើ</u>សុំប្រាក់ជំនួយថ្លៃសិក្សាសម្រាប់វិទ្យាល័យនិងស្ថាប័នអប់រំស្មើវិទ្យាល័យនៅការិយាល័យរដ្ឋបាលនៃសាលាដែលអ្នកកំពុងសិក្សា។

## ◆ វិធីដាក់ពាក្យស្នើសុំ

សូមបំពេញទម្រង់លេខ1-1 **ពាក្យស្នើសុំទទួលស្គាល់សិទ្ធិទទួលប្រាក់ជំនួយថ្លៃសិក្សាវិទ្យាល័យ និងស្ថាប័នអប់រំដែលមានកម្រិតស្មើវិទ្យាល័យ**
ចំពោះ **សិស្សដែលកំពុងសិក្សានៅសាលា និងបានទទួលការទទួលស្គាល់សិទ្ធិទទួលប្រាក់ជំនួយរួចហើយ** សូមបំពេញ **ទម្រង់លេខ ១-២ ពាក្យស្នើសុំបញ្ជាក់សិទ្ធិទទួលប្រាក់ជំនួយថ្លៃសិក្សាវិទ្យាល័យ និងស្ថាប័នអប់រំដែលមានកម្រិតស្មើវិទ្យាល័យ**។
សូមភ្ជាប់ឯកសារខាងក្រោម (បិទភ្ជាប់លើសន្លឹកសម្រាប់បិទឯកសារដោយប្រើកាវ)ហើយដាក់ស្នើទៅកាន់ការិយាល័យរដ្ឋបាលរបស់សាលា។

◆ ឯកសារចាំបាច់
(<u>តម្រូវអោយសិស្សដាក់</u>ឯកសារណាមួយដែលមាននៅខាងក្រោមនេះ។ <u>សម្រាប់សិស្សដែលមានសញ្ជាតិជប៉ុន មិនតម្រូវអោយដាក់នោះទេ។</u>)

☐លិខិតបញ្ជាក់ទីលំនៅ ឯកសារដើម
☐ច្បាប់ចម្លងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ពិសេស
☐ច្បាប់ចម្លងប័ណ្ណស្នាក់នៅ

☐(សម្រាប់អ្នកមានស្ថានភាពស្នាក់នៅប្រភេទ「家族滞在」តម្រូវអោយដាក់បន្ថែម)
ច្បាប់ចម្លងសញ្ញាបត្របញ្ចប់ការសិក្សាឬលិខិតបញ្ជាក់ការបញ្ចប់ការសិក្សាពីសាលាបឋមសិក្សានិងអនុវិទ្យាល័យនៅប្រទេសជប៉ុន

## ◆ ដំណើរការនៃការដាក់ពាក្យ

ខែមេសា ឆ្នាំ២០២៦ដល់ខែមីនា ឆ្នាំ២០២៧

**【ឯកសារត្រូវដាក់សម្រាប់ការត្រួតពិនិត្យ】**

1 ១ពាក្យស្នើសុំទទួលសិទ្ធិសម្រាប់ថវិកាជំនួយថ្លៃសិក្សាវិទ្យាល័យ
(សម្រាប់សិស្សកំពុងសិក្សាដែលបានទទួលការអនុម័តរួចហើយ ត្រូវដាក់ពាក្យបញ្ជាក់សិទ្ធិទទួលប្រាក់ជំនួយ)

2 ២សន្លឹកភ្ជាប់ច្បាប់ចម្លងប័ណ្ណស្នាក់នៅ និងឯកសារពាក់ព័ន្ធ
(សូមភ្ជាប់ឯកសារមួយក្នុងចំណោមឯកសារខាងក្រោមរបស់សិស្ស។ ប្រសិនបើមានសញ្ជាតិជប៉ុន មិនចាំបាច់ដាក់ទេ)
□លិខិតបញ្ជាក់ទីលំនៅ
□ច្បាប់ចម្លងវិញ្ញាបនបត្រអ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស
□ច្បាប់ចម្លងប័ណ្ណស្នាក់នៅ

(សម្រាប់អ្នកមានស្ថានភាពស្នាក់នៅប្រភេទ「家族滞在」តម្រូវអោយដាក់ឯកសារខាងក្រោមបន្ថែមផងដែរ)
□ច្បាប់ចម្លងសញ្ញាបត្រ ឬលិខិតបញ្ជាក់ការបញ្ចប់ការសិក្សា ពីសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅប្រទេសជប៉ុន

↓

**ការត្រួតពិនិត្យសិទ្ធិទទួលប្រាក់ជំនួយថ្លៃសិក្សា**

↓

| 【សិស្សចូលថ្មី សិស្សកំពុងសិក្សា】 | 【សិស្សកំពុងសិក្សា】 | 【សិស្សកំពុងសិក្សា】 | 【សិស្សចូលថ្មី】 |
| --- | --- | --- | --- |
| សម្រាប់អ្នកដែលស្ថិតក្នុងចំណោម「សិស្សដែលមានសិទ្ធិទទួល」មានបញ្ជាក់នៅទំព័រ១ | ទោះបីជាមិនស្ថិតក្នុងចំណោម「សិស្សដែលមានសិទ្ធិទទួល」ក៏ដោយប៉ុន្តែសម្រាប់គ្រួសារដែលមានចំណូលប្រចាំឆ្នាំប្រហែលក្រោម ៩១០ម៉ឺនយ៉េនដូចមានបញ្ជាក់នៅទំព័រ១ | ទោះបីជាមិនស្ថិតក្នុងចំណោម「សិស្សដែលមានសិទ្ធិទទួល」គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល ៩១០ម៉ឺនយ៉េន ឬលើសពីនេះ | <u>សម្រាប់សិស្សដែលមិនត្រូវនឹងលក្ខខណ្ឌ</u>「សិស្សដែលមានសិទ្ធិទទួល」ដូចបានបញ្ជាក់នៅទំព័រ១ |
| ↓ | ↓ | ↓ | ↓ |
| **ការផ្តល់ថវិកាជំនួយថ្លៃសិក្សា** ប្រាក់ជំនួយនេះ មិនមែនជាប្រាក់ដែលផ្តល់ជូនដល់អ្នកដោយផ្ទាល់ឡើយ។សាលារៀននឹងយកថវិកានេះទៅប្រើសម្រាប់ទូទាត់ថ្លៃសិក្សា ដូច្នេះ <u>ការបង់ថ្លៃសិក្សានឹងមិនចាំបាច់ទៀតទេ</u>។ | (same) | **មិនអនុម័តផ្តល់ថវិកាជំនួយថ្លៃសិក្សា※** | (same) |

↓

**សេចក្តីជូនដំណឹងអំពីលទ្ធផលនៃការត្រួតពិនិត្យ** [ផ្ញើតាមប្រៃសណីយ៍ ]

※ ទោះបីជាមិនត្រូវនឹងលក្ខខណ្ឌ「សិស្សដែលមានសិទ្ធិទទួល」ហើយមិនទទួលបានប្រាក់ជំនួយថ្លៃសិក្សាក៏ដោយ ក៏នៅមានប្រព័ន្ធជំនួយមួយផ្សេងទៀត (新修学支援金) ដែលអាចទទួលបាន ដោយផ្អែកលើលក្ខខណ្ឌប្រាក់ចំណូល។

## ◆ លក្ខខណ្ឌទាក់ទងនឹងសញ្ជាតិ និងស្ថានភាពស្នាក់នៅ

<table>
<tr><th>ប្រភេទ</th><th colspan="2">ឧទាហរណ៍</th><th>រយៈពេលស្នាក់នៅ</th><th>សិទ្ធិទទួលថវិកាជំនួយ</th><th>(ព័ត៌មានបន្ថែម)</th></tr>
<tr><td>① អ្នកមានសញ្ជាតិជប៉ុន</td><td colspan="2">ជនជាតិជប៉ុន ឬជនបរទេសដែលបានចូលសញ្ជាតិជប៉ុន</td><td>—</td><td>មានសិទ្ធិទទួល</td><td></td></tr>
<tr><td>② អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស (特別永住者)</td><td colspan="2">អ្នកដែលមានស្ថានភាពស្នាក់នៅអចិន្ត្រៃយ៍ពិសេសនៅប្រទេសជប៉ុន</td><td>គ្មានកំណត់</td><td>មានសិទ្ធិទទួល</td><td></td></tr>
<tr><td rowspan="3">③ អ្នកស្នាក់នៅអចិន្ត្រៃយ៍ ។ល។</td><td>អ្នកស្នាក់នៅអចិន្ត្រៃយ៍</td><td>អ្នកដែលបានទទួលការអនុញ្ញាតឱ្យស្នាក់នៅអចិន្ត្រៃយ៍ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌</td><td>គ្មានកំណត់</td><td rowspan="3">មានសិទ្ធិទទួល</td><td rowspan="3"></td></tr>
<tr><td>ប្ដី/ប្រពន្ធរបស់ជនជាតិជប៉ុន</td><td>ប្ដី ឬប្រពន្ធរបស់ជនជាតិជប៉ុន កូនបង្កើត ឬកូនចិញ្ចឹមពិសេស</td><td>៥ឆ្នាំ, ៣ឆ្នាំ, ១ឆ្នាំ ឬ ៦ខែ</td></tr>
<tr><td>ប្ដី/ប្រពន្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍</td><td>ប្ដី ឬប្រពន្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍ ឬអ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស និងកូនដែលកើតនៅប្រទេសជប៉ុន ហើយបន្តស្នាក់នៅក្នុងប្រទេសជប៉ុនជាបន្តបន្ទាប់</td><td>៥ឆ្នាំ, ៣ឆ្នាំ, ១ឆ្នាំ ឬ ៦ខែ</td></tr>
<tr><td>④ អ្នកស្នាក់នៅរយៈពេលកំណត់ (定住者)</td><td colspan="2">អ្នកដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អនុញ្ញាតឱ្យស្នាក់នៅដោយមានហេតុផលពិសេស (ឧ. ជនភៀសខ្លួនពីប្រទេសទី៣, ជនជាតិជប៉ុនដែលត្រឡប់មកវិញពីចិន ។ល។)</td><td>៥ឆ្នាំ, ៣ឆ្នាំ, ១ឆ្នាំ ឬ ៦ខែ ឬរយៈពេលដែលកំណត់ដោយរដ្ឋមន្ត្រី (មិនលើស ៥ឆ្នាំ)</td><td>ក្នុងចំណោមអ្នកស្នាក់នៅប្រភេទនេះ អ្នកដែលត្រូវបានទទួលស្គាល់ថាមានបំណងក្លាយជាអ្នកស្នាក់នៅអចិន្ត្រៃយ៍ នឹងមានសិទ្ធិទទួល</td><td rowspan="3">●សម្រាប់សិស្សកំពុងសិក្សា <u>(រួមទាំងសិស្សអន្តរជាតិ)</u> ដែលមិនស្ថិតក្នុងវិសាលភាពនៃប្រព័ន្ធថ្មី នឹងបន្តទទួលការគាំទ្រតាមប្រព័ន្ធចាស់។<br><br>●សម្រាប់សិស្សចូលថ្មីដែលមិនស្ថិតក្នុងវិសាលភាពនៃប្រព័ន្ធថ្មី <u>(មិនរាប់បញ្ចូលសិស្សអន្តរជាតិ)</u> នឹងទទួលបានការគាំទ្រផ្នែកថវិកាក្នុងកម្រិតស្មើនឹងប្រព័ន្ធចាស់។</td></tr>
<tr><td>⑤ ស្នាក់នៅជាមួយគ្រួសារ (家族滞在)</td><td colspan="2">កូនរបស់អ្នកដែលមានស្ថានភាពស្នាក់នៅជាគ្រូបង្រៀន សិល្បករ ជាដើម</td><td>រយៈពេលដែលកំណត់ដោយរដ្ឋមន្ត្រី (មិនលើស ៥ឆ្នាំ)</td><td>ក្នុងចំណោមអ្នកស្នាក់នៅជាមួយគ្រួសារ អ្នកដែលបានបញ្ចប់បឋមសិក្សា និងមធ្យមសិក្សានៅជប៉ុន ហើយត្រូវបានទទួលស្គាល់ថាមានបំណងរស់នៅ និងធ្វើការនៅជប៉ុន នឹងមានសិទ្ធិទទួល</td></tr>
<tr><td>⑥ អ្នកស្នាក់នៅក្រោមស្ថានភាពស្នាក់នៅផ្សេងៗ</td><td colspan="2">ការទូត, កិច្ចការផ្លូវការ, សកម្មភាពវប្បធម៌, សិក្សា, បណ្ដុះបណ្ដាល, សកម្មភាពជាក់លាក់ ជាដើម</td><td>១៥ថ្ងៃ ដល់ ៥ឆ្នាំ អាស្រ័យលើប្រភេទ</td><td>មិនមានសិទ្ធិទទួល</td></tr>
</table>

※ការទទួលបាន ការផ្លាស់ប្ដូរ ឬការបន្តស្ថានភាពស្នាក់នៅទាំងអស់ ត្រូវការការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ◆ អំពីអាហារូបករណ៍ជំនួយការសិក្សាថ្មី និងជំនួយថ្លៃសិក្សា (វិធានការបន្តអន្តរកាល)

ប្រសិនបើមិនស្ថិតក្នុងចំណោម「**សិស្សដែលមានសិទ្ធិទទួលជំនួយ**」ដែលបានបញ្ជាក់នៅទំព័រP1ទេប្រភេទជំនួយដែលអាចទទួលបាននឹងខុសគ្នាដោយផ្អែកលើចំនួនប្រាក់ចំណូលរបស់អាណាព្យាបាល ដែលគណនាតាមរូបមន្តដែលបានកំណត់។

| |
|---|
| 【គណនា】ចំនួនមូលដ្ឋានពន្ធរបស់ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ × 6 % − ចំនួនទឹកប្រាក់នៃការកាត់បន្ថយពន្ធ |

※ ក្នុងករណីរស់នៅក្នុងទីក្រុងដែលកំណត់ដោយរដ្ឋបាលជាតិ ចំនួនទឹកប្រាក់នៃ ការកាត់បន្ថយពន្ធ ត្រូវគណនាដោយយក **3/4 (បីភាគបួន)** នៃចំនួនទឹកប្រាក់នោះ។

※ ប្រសិនបើសិស្សដែលស្នើសុំទទួលជំនួយថ្លៃសិក្សាកើតនៅដើមឆ្នាំហើយការអនុវត្តការកាត់បន្ថយសម្រាប់បុត្រធីតាក្នុងបន្ទុកត្រូវពន្យារពេល ១ឆ្នាំបើប្រៀបធៀបនឹងសិស្សផ្សេងទៀតក្នុងថ្នាក់ដូចគ្នា នោះត្រូវគណនាដោយដក **330,000យ៉េន** ចេញពីមូលដ្ឋានពន្ធរបស់អាណាព្យាបាលជាមុនសិន។

| ប្រភេទ | គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែលក្រោម910 លានយ៉េន | គ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំប្រហែល910លានយ៉េនឬច្រើនជាងនេះ |
|---|---|---|
| សិស្សដែលកំពុងសិក្សា(រួមទាំងសិស្សបរទេស) ដែល<u>មិនស្ថិតក្រោមប្រព័ន្ធថ្មី</u> | ទទួលបានជំនួយថ្លៃសិក្សា(វិធានការបន្តអន្តរកាល) | ទទួលបានអាហារូបករណ៍ជំនួយការសិក្សាថ្មី |
| សិស្សចូលរៀនថ្មីដែលមិនស្ថិតក្រោមប្រព័ន្ធថ្មី (មិនរាប់បញ្ចូលសិស្សបរទេស) | ទទួលបានអាហារូបករណ៍ជំនួយការសិក្សាថ្មី | |

※　ចំនួនប្រាក់ចំណូលប្រចាំឆ្នាំខាងលើគ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។អាស្រ័យលើការកាត់បន្ថយពន្ធឬលក្ខខណ្ឌផ្សេងៗ ទោះបីជាប្រាក់ចំណូលលើស 910ម៉ឺនយ៉េនក៏ដោយ ក៏អាចត្រូវបានអនុម័តថាមានសិទ្ធិទទួលជំនួយបានដែរ។

## ◆ របៀបដាក់ពាក្យ

សិស្សដែលត្រូវដាក់របាយការណ៍អំពីស្ថានភាពប្រាក់ចំណូលសម្រាប់ការពិនិត្យសិទ្ធិទទួលជំនួយថ្លៃសិក្សាឬសិស្សដែលមិនត្រូវបានផ្ដល់ជំនួយថ្លៃសិក្សានឹងទទួលបានសេចក្ដីជូនដំណឹង និងឯកសារពាក់ព័ន្ធនៅពេលក្រោយ។សូមបញ្ជូនឯកសារចាំបាច់ទាំងអស់ទៅសាលារៀន មុនថ្ងៃផុតកំណត់ ដែលបានកំណត់។

## ◆ សំណួរដែលគេសួរញឹកញាប់ (FAQ)



**Q** ទោះបីជាលក្ខខណ្ឌកំណត់ប្រាក់ចំណូល ត្រូវបានលុបចោលហើយ ក៏នៅតែត្រូវដាក់ពាក្យដែរឬទេ?

**A** **ត្រូវដាក់ពាក្យ**។ទោះបីជាលក្ខខណ្ឌកំណត់ប្រាក់ចំណូលត្រូវបានលុបចោលក៏ដោយក៏នៅតែចាំបាច់ត្រូវពិនិត្យបញ្ជាក់អំពី **សញ្ជាតិ** (国籍) និង **ស្ថានភាពស្នាក់នៅ** (在留資格) ជាដើម។ ដូច្នេះ សូមដាក់ពាក្យស្នើសុំជាចាំបាច់។



## ◆ សូមទាក់ទងការិយាល័យសាលាជាបន្ទាន់ ក្នុងករណីដូចខាងក្រោម

◇ នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន

◇ ពេលមានការផ្លាស់ប្តូរសញ្ជាតិ ឬស្ថានភាពស្នាក់នៅ ឬមានការបន្តរយៈពេលស្នាក់នៅ ជាដើមក្នុងករណីទាំងនេះ ត្រូវអនុវត្តនីតិវិធីបន្ថែមដោយឡែក។

## ◆ ឯកសារយោង

①ប្រព័ន្ធដាក់ពាក្យអនឡាញសម្រាប់ជំនួយថ្លៃ

e-Shien

ដាក់ពាក្យនៅទីនេះ

②គេហទំព័រក្រសួងអប់រំ

ខិត្តប័ណ្ណ សេចក្តីសង្ខេបអំពីប្រព័ន្ធ

③គេគេហទំព័រគណៈកម្មការអប់រំខេត្តកាណាហ្គាវ៉ា

ព័ត៌មានជូនដំណឹងផ្សេងៗដែលបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់

សម្រាប់ការសាកសួរសូមទាក់ទង　ការិយាល័យរដ្ឋបាលនៃវិទ្យាល័យរដ្ឋខេត្តកាណាហ្គាវ៉ា　ទូរស័ព្ទ　　　　－　　　　－